ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រសួងសុខាភិបាល

# របាយការណ៍សង្ខេប

# តួលេខប៉ាន់ស្មានសំរាប់ជំងឺអេដស៍នៅប្រទេសកម្ពុជា ឆ្នាំ២០១០-២០១៥

ផ្នែកអង្កេតតាមដាន

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

# Contents


សេចក្តីផ្តើម ........ 3

គោលបំណង ........ 4

វិធីសាស្រ្ត ........ 5

១. ការប៉ាន់ស្មានអត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមក្រុមប្រជាជនទូទៅ ........ 6

រូបភាពទី១. វិធីសាស្រ្តដែលប្រើប្រាស់ សំរាប់ការប៉ាន់ស្មានរកអត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមក្រុមប្រជាជនទូទៅ(១៥ ដល់ ៤៩ឆ្នាំ) ........ 7

២.វិធីសាស្រ្តសំរាប់ធ្វើការប៉ាន់ស្មានតួលេខមេរោគអេដស៍/ជំងឺអេដស៍ ឆ្នាំ២០១០-២០១៥ ........ 7

រូបភាពទី២: វិធីសាស្រ្តដែលប្រើសំរាប់ធ្វើការប៉ាន់ស្មានតួលេខមេរោគអដស៍/ជំងឺអេដស៍ ........ 9

លទ្ធផល៖ ........ 10

១. អត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមស្រ្តីអាយុ ១៥ ដល់ ៤៩ឆ្នាំ ក្នុងដំណាក់ការសេវាថៃទាំ និងព្យាបាលជំងឺអេដស៍មានការគ្រប់ដណ្តប់ខ្ពស់ ........ 10

តារាងទី១៖ សង្ខេបទិន្នន័យសំរាប់ការប៉ានស្មានមេរោគអេដស៍ របស់ស្រ្តីទូទៅ នៅក្នុងកំឡុងពេលដែលសេវាថៃទាំ និងព្យាបាលជំងឺអេដស៍ដែលមានការគ្រប់ដណ្តប់ខ្ពស់ ........ 11

រូមភាពទី៣៖អត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមប្រជាជនទូទៅអាយុ១៥ដល់៤៩ ក្នុងឆ្នាំ២០១០ ........ 12

២. តួលេខប៉ាន់ស្មានអត្រាប្រេវ៉ាឡង់មេរោគអេដស៍ ក្នុងចំណោមក្រុមប្រជាជន ទូទៅ អាយុ ១៥ ដល់ ៤៩ឆ្នាំ ........ 12

រូបភាពទី៤៖ និន្នាការនៃអត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមប្រជាជនទូទៅអាយុ១៥ដល់ ៤៩ឆ្នាំ (from spectrum) ........ 13

រូបភាពទី៥៖ និន្នាកានៃអត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមប្រជាជនទូទៅអាយុ ១៥ឡើងទៅ (from AEM) ........ 13

រូបភាពទី៦៖ និន្នាកានៃអត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមក្រុមប្រជាជនទូទៅ តាមក្រុមអាយុ . 14

រូបភាពទី៧៖ ចំនួនប្រជាជនទូទៅដែលបានឆ្លងមេរោគអេដស៍ក្នុងចំណោមអ្នកមានអាយុ១៥ឆ្នាំឡើង (from Spectrum) ........ 14

រូបភាពទី៨៖ ចំនួនប្រជាជនទូទៅដែលមានផ្ទុក មេរោគអេដស៍ចាប់ពីអាយុ ១៥ ឆ្នាំឡើងទៅ (Spectrum) ........ 15

រូបភាពទី៩៖ ចំនួនអ្នកជំងឺអេដស៍ក្នុងចំណោមប្រជាជនទូទៅអាយុ១៥ឆ្នាំឡើង (from Spectrum) ........ 15

រូបភាពទី១០៖ ចំនួនអ្នកជំងឺអេដស៍ដែលត្រូវការឱសថប្រឆាំងមេរោគអេដស៍ អាយុចាប់ពីអាយុ ១៥ ឆ្នាំ ឡើងទៅ ........ 16

រូបភាពទី១១៖ ចំនួនអ្នកស្លាប់ដោយសារមេរោគអេដស៍ ក្នុងចំណោមមនុស្សពេញវ៉យអាយុ១៥ឆ្នាំឡើង(from Spectrum) ........ 16

រូបភាពទី១២៖ ចំនួនកុមារដែលមានផ្ទុកមេរោគអេដស៍ ដែលមានអាយុចាប់ពី ០-១៤ ឆ្នាំ (Spectrum) ... 17
រូបភាពទី១៣៖ ចំនួនអ្នកជំងឺអេដស៍ក្នុងចំណោមកុមារដែលមានអាយុចាប់០ ដល់ ១៤ឆ្នាំ (from Spectrum) ........ 17
រូបភាពទី១៤៖ ចំនួនកុមារដែលមានផ្ទុកមេរោគអេដស៍ អាយុចាប់ពី ០-១៤ ឆ្នាំ ត្រូវការសេវាឱសថប្រឆាំង មេរោគ អេដស៍ (Spectrum)........ 18
រូបភាពទី១៥៖ ចំនួនអ្នកស្លាប់ដោយសារមេរោគអេដស៍ ក្នុងចំណោមកុមារអាយុ ០ ដល់ ១៥ឆ្នាំ........ 18
រូបភាពទី១៦៖ ចំនួនកុមារកំព្រាដោយសារមេរោគអេដស៍ សរុប........ 19
រូបភាពទី១៧៖ ការប៉ាន់ស្មានចំនួនស្ត្រី មានផ្ទៃពោះដែលមានផ្ទុកមេរោគអេដស៍ដែលបានទទួលសេវា PMTCT........ 19
រូបភាពទី១៨៖ ការប៉ាន់ស្មានអត្រាឆ្លងមេរោគអេដស៍ពីម្តាយទៅកូន (from Spectrum)...**Error! Bookmark not defined.**
រូបភាពទី១៩៖ ប្រភពនៃការ ចំលងមេរោគមេរោគអេដស៍ក្នុងចំណោមអ្នកឆ្លង ថ្មី........ 20
រូបភាពទី២០៖ ចំនួនករណីឆ្លងថ្មីបែងចែកទៅតាមប្រភពចំលងមេរោគអេដស៍........ 21
**រូបភាពទី២១៖** ភាគរយនៃករណីឆ្លងថ្មីបែងចែកតាមប្រភពនៃការឆ្លងមេរោគអេដស៍........ 21
ការពិភាក្សា........ 22
ការសន្និដ្ឋាន........ 23

# អារម្ភកថា

ការរីករាលដាលនៃមេរោគអេដស៍-ជម្ងឺអេដស៍ នៅប្រទេសកម្ពុជាបានឈានចូលដល់ឆ្នាំទី២០ ហើយ បើគិតចាប់តាំងពីពេលដែលមេរោគអេដស៍ត្រូវបានរកឃើញដំបូងនៅឆ្នាំ ១៩៩១។ ប្រទេសកម្ពុជាទទួលបានជោគជ័យ ក្នុងការធ្វើឲ្យអត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមប្រជាជនទូទៅ ថយចុះដល់ ០,៨ភាគរយនៅឆ្នាំ២០១០ ហើយអត្រាប្រេវ៉ាឡង់មេរោគអេដស៍ត្រូវបានប៉ាន់ស្មានថា នឹងនៅត្រឹមប្រហែល ០,៦ ភាគរយរហូតដល់ឆ្នាំ ២០១៥។

ការធ្វើការប៉ាន់ស្មាននូវនិន្នាការ រីករាលដាលនៃមេរោគអេដស៍ និងផលប៉ះពាល់របស់វានាពេលអនាគតមិនមែនជាការងាយស្រួលទេ ព្រោះវាទាមទារនូវការប្រឹងប្រែង និងការប្ដេជ្ញាចិត្តពីគ្រប់ដៃគូទាំងអស់ រួមទាំងរាជរដ្ឋាភិបាល ភ្នាក់ងារអភិវឌ្ឍន៍ និងអ្នកដែលធ្វើការពាក់ពន្ធ័ទាំងអស់ ក្រោមការដឹកនាំនិងភាពជាម្ចាស់ដ៏រឹងមាំនៃប្រទេស ដែលកំពុងអនុវត្តនូវកម្មវិធីទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍។ វាក៏ទាមទារផងដែរនូវការសហការគ្នាទៅវិញទៅមក រវាងអ្នកវិទ្យាសាស្ត្រជំនាញផ្នែកសុខភាព និងអ្នកអនុវត្តកម្មវិធីទប់ស្កាត់ការរីករាលដាល នៃមេរោគអេដស៍-ជម្ងឺអេដស៍ និងទាមទារឲ្យមានការយល់ដឹងផង អំពីការប្រើប្រាស់នូវតួលេខចេញពីការប៉ាន់ស្មាននេះ។

ទោះបីជាមានភាពស្មុគ្រស្មាញយ៉ាងនេះក៏ដោយ ក៏មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និងកាមរោគ បានធ្វើការប៉ាន់ស្មានអត្រាប្រេវ៉ាឡង់មេរោគអេដស៍-ជម្ងឺអេដស៍បានជោគជ័យ ចំនួន៣លើករួចហើយ គឺនៅ ឆ្នាំ២០០០ ឆ្នាំ២០០៣ និងឆ្នាំ២០០៧ ហើយតួលេខនៃការប៉ាន់ស្មានទាំងនេះ ត្រូវបានយកទៅប្រើប្រាស់យ៉ាងទូលំទូលាយ។

របាយការណ៍នេះ ជារបាយការណ៍ នៃការប៉ាន់ស្មានអត្រាប្រេវ៉ាឡង់មេរោគអេដស៍ប្រចាំឆ្នាំ ២០១១ ដែលចងក្រងការធ្វើការប៉ាន់ស្មានអត្រាប្រេវ៉ាឡង់មេរោគអេដស៍ ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៥។ របាយការណ៍នេះ ជាលទ្ធផលនៃការប្រឹងប្រែងរួមគ្នានៃគ្រប់ដៃគូអភិវឌ្ឍន៍ទាំងអស់ រួមទាំងអ្នកដែលធ្វើការពាក់ពន្ធ័ និងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និង កាមរោគ នៅក្រោមការចង្អុលបង្ហាញរបស់ក្រសួង សុខាភិបាល។

ក្រសួងសុខាភិបាល សូមជំរុញឲ្យប្រើប្រាស់តួលេខនៃការប៉ាន់ស្មាននៅក្នុងរបាយការណ៍នេះ ដើម្បីធ្វើឲ្យមានភាពប្រសើរឡើងកាន់តែខ្លាំងថែមទៀត ក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍-ជម្ងឺអេដស៍ និងដើម្បីកាត់បន្ថយផលប៉ះពាល់របស់មេរោគអេដស៍-ជម្ងឺអេដស៍ ទៅលើប្រជាជន។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០១២

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

ម៉ម_ប៊ុនហេង

# សេចក្តីផ្តើម

ការរីករាលដាលនៃមេរោគអេដស៍នៅប្រទេសកម្ពុជា បានឈានដល់ឆ្នាំទី២០ហើយ បើគិតចាប់ពីពេលដែលរកឃើញមេរោគអេដស៍ជាលើកដំបូង នៅឆ្នាំ១៩៩១ ។ រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសង្គមស៊ីវិល ដោយមានការគាំទ្រទាំងថវិកា និងបច្ចេកទេសពីដៃគូអភិវឌ្ឍន៍បានឆ្លើយតបយ៉ាងសកម្ម ដើម្បីទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ រហូតដល់ប្រទេសកម្ពុជាទទួលបានជោគជ័យ ក្នុងការធ្វើអោយអត្រាប្រេវ៉ាឡង់មេរោគអេដស៍ថយចុះមកត្រឹមប្រហែល០.៩%នៅឆ្នាំ២០០៦ ក្នុងចំណោមក្រុមប្រជាជនទូទៅ[១]។

ស្របពេលជាមួយគ្នានេះ សេវាថែទាំ និងព្យាបាលជំងឺអេដស៍ ក៏ត្រូវបានពង្រីកយ៉ាងទូលំទូលាយ ដើម្បីឆ្លើយតបទៅនឹងការកើនឡើង នៃចំនួនអ្នកផ្ទុកមេរោគអេដស៍ដែលត្រូវការឱសថប្រឆាំងមេរោគអេដស៍ ។ ជាលទ្ធផលការគ្របដណ្តប់ របស់សេវាថែទាំ និងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍ ដែលត្រូវការឱសថប្រឆាំងមេរោគអេដស៍នៅប្រទេសកម្ពុជា បានកើនឡើងយ៉ាងខ្លាំងពីតិចជាង១០% ក្នុងឆ្នាំ២០០៣ ទៅ ៨០% គិតមកត្រឹមខែកញ្ញា ឆ្នាំ២០០៧ ។ បើគិតត្រឹមខែមិថុនា ឆ្នាំ២០១១ នៅទូទាំងប្រទេសកម្ពុជា មានមណ្ឌលផ្តល់សេវាថែទាំ និងព្យាបាលជំងឺអេដស៍ចំនួន៥៦មណ្ឌលផ្តល់សេវាថែទាំ និងព្យាបាលជំងឺអេដស៍ (នៅក្នុងចំណោម៥៦មណ្ឌលនោះ មានផ្តល់សេវាសំរាប់មនុស្សពេញវ័យ និងសំរាប់កុមារចំនួន ៣១មណ្ឌល សំរាប់មនុស្សពេញវ័យមានចំនួន ២៣មណ្ឌល និងសំរាប់តែកុមារមានចំនួន ២មណ្ឌល) ដែលកំពុងផ្តល់សេវាថែទាំ និងព្យាបាលជំងឺ ដល់មនុស្សពេញវ័យ ដែលមានផ្ទុកមេរោគអេដស៍ចំនួន៤០.៨៣៦នាក់ និងកុមារមានផ្ទុកមេរោគអេដស៍ចំនួន៤.២៨៦នាក់ (កុមារ គឺគិតអាយុតិចជាង១៥ឆ្នាំ) ។

នៅក្នុងការឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍/ជំងឺអេដស៍ កម្មវិធីជាតិប្រយុទ្ធនឹងជំងឺអេដស៍ អាចនឹងជួបប្រទះការលំបាកជាច្រើន ប្រសិនបើគ្មានពត៌មាន ជាយុទ្ធសាស្រ្ត អំពីមេរោគអេដស៍/ជំងឺអេដស៍ ជាពិសេសគឺ ជួបការលំបាកក្នុងការធ្វើអន្តរាគមន៍ទៅលើមេរោគអេដស៍/ជំងឺអេដស៍ក្នុងចំណោមក្រុមប្រជាជនទូទៅ (អាយុ ១៥

ដល់ ៤៩ឆ្នាំ) ។ ពត៌មានយុទ្ធសាស្ត្រនេះ ក៏អាចប្រើប្រាស់ផងដែរ សំរាប់ធ្វើគំរោងផែនការ និងសកម្មភាពគ្រប់គ្រងការបង្កាការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ។

បច្ចុប្បន្ននេះ ប្រព័ន្ធអង្កេតតាមដានអំពីមេរោគអេដស៍/ជំងឺអេដស៍របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ មានតែទិន្នន័យ ដែលប្រមូលមកយកពីក្រុមប្រឈមមុខខ្ពស់ និងក្រុមស្ត្រីដែលមកពិនិត្យផ្ទៃពោះនៅមណ្ឌលសុខភាពតែប៉ុណ្ណោះ ហើយការធ្វើអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជានៅឆ្នាំ២០១០ ក៏មិនបានប្រមូលពត៌មានលើអត្រាប្រេវ៉ាឡង់មេរោគអេដស៍ នៅលើក្រុមប្រជាជនទូទៅដែរ។ ដោយសារកត្តាខាងលើនេះហើយ ដើម្បីរកអោយឃើញនូវអត្រាប្រេវ៉ាឡង់មេរោគអេដស៍ ក្នុងចំណោមក្រុមប្រជាជនទូទៅ(១៥ ដល់ ៤៩ឆ្នាំ) មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ត្រូវធ្វើការប៉ាន់ស្មាន ដោយប្រើប្រាស់ទិន្នន័យទាំងអស់ ដែលប្រមូលបានមកពីក្រុមប្រឈមមុខផ្សេងៗ បូកផ្សំនឹងការប្រើប្រាស់វិធីសាស្ត្រប៉ាន់ស្មាន់ដែលមានលក្ខណៈវិទ្យាសាស្ត្រ ។

ចាប់តាំងពីឆ្នាំ២០០០មក មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានទទួលជោគជ័យ ក្នុងការធ្វើការប៉ាន់ស្មានតួលេខមេរោគអេដស៍/ជំងឺអេដស៍ ៣ លើករួចមកហើយ (ឆ្នាំ២០០០, ២០០៣ និង២០០៧) ។ កិច្ចប្រជុំប៉ាន់ស្មានតួលេខមេរោគអេដស៍/ជំងឺអេដស៍លើកចុងក្រោយ ត្រូវបានធ្វើឡើងនៅឆ្នាំ២០០៧ ដើម្បីធ្វើការប៉ាន់ស្មានអត្រាប្រេវ៉ាឡង់មេរោគអេដស៍/ជំងឺអេដស៍ចាប់ពីឆ្នាំ២០០៦ ដល់ ឆ្នាំ២០១២។ ដូចនេះ ដើម្បីឆ្លើយតបទៅនឹងតំរូវការតួលេខមេរោគអេដស៍/ជំងឺអេដស៍ថ្មីសំរាប់ឆ្នាំ២០១១ ដល់ ឆ្នាំ២០១៥ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ នឹងធ្វើការប៉ាន់ស្មានអត្រាប្រេវ៉ាឡង់មេរោគអេដស៍/ជំងឺអេដស៍ឆ្នាំ ២០១១ ដល់ ២០១៥ ដើម្បីជាប្រយោជន៍ សំរាប់គ្រប់ស្ថាប័ន្តជាតិ និងអន្តរជាតិ ដែលធ្វើការងារពាក់ពន្ធ័នឹងជំងឺអេដស៍/ជំងឺអេដស៍ ។

# គោលបំណង

គោលបំណងចំបងនៃការប៉ាន់ស្មានតួលេខមេរោគអេដស៍/ជំងឺអេដស៍គឺដើម្បីៈ

ពិនិត្យឡើងវិញ នូវទិន្នន័យនៃអត្រាប្រេវ៉ាឡង់មេរោគអេដស៍ ដែលបានមកពីប្រភពសំខាន់ៗ (ការអង្កេតឈាមរកអត្រាប្រេវ៉ាឡង់មេរោគអេដស៍២០១០ ការអង្កេតរកអត្រាប្រេវ៉ាឡង់មេរោគអេដស៍ ក្នុងចំណោមក្រុមបុរសរួមភេទជាមួយបុរស និងប្រភពផ្សេងៗទៀត ដែលអាចមាន) ។

– កំណត់វិធីសាស្ត្រ និងការសន្មត់សំរាប់ការប៉ាន់ស្មានអត្រាប្រេវ៉ាឡង់មេរោគអេដស៍ និងការឆ្លងមេរោគអេដស៍ថ្មី ក្នុងប្រទេសកម្ពុជា ដោយយកអត្រាប្រេវ៉ាឡង់មេរោគអេដស៍ ក្នុងចំណោមស្ត្រីមកពិនិត្យផ្ទៃពោះ ឆ្នាំ២០១០ ជាគោល ។

– ប៉ាន់ស្មានថ្នាក់ជាតិ ពីអត្រាប្រេវ៉ាឡង់មេរោគអេដស៍ ការឆ្លងមេរោគអេដស៍ថ្មី និងការស្លាប់ដោយសារមេរោគអេដស៍ ក្នុងប្រទេសកម្ពុជា។

– ប៉ាន់ស្មានសូចនាករផ្សេងៗទៀត ដែលទាក់ទងនឹងមេរោគអេដស៍/ជំងឺអេដស៍ សំរាប់ការអនុវត្តន៍កម្មវិធីបង្ការការឆ្លងមេរោគអេដស៍។

# វិធីសាស្ត្រ

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ជាអ្នកដឹកនាំការងារធ្វើការប៉ាន់ស្មានតួលេខមេរោគអេដស៍/ជំងឺអេដស៍ ។ សមាជិកទាំងអស់ ដែលបានចូលរួមមានៈ តំណាងពីមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ (ផ្នែកអង្កេតតាមដាន និងផ្នែកស្រាវជ្រាវ) តំណាងពីវិទ្យាស្ថានជាតិស្ថិតិ នាយកដ្ឋានផែនការនៃក្រសួងសុខាភិបាល អង្គការសុខភាពពិភពលោក UNAIDS, CDC, CHAI, អង្គការសុខភាពគ្រួសារអន្តរជាតិ (FHI), និងទីប្រឹក្សាជាតិ និងអន្តរជាតិ ។

ដោយសារការងារប៉ាន់ស្មានមានទំហំធំ យើងបានរៀបចំអោយមានសិក្ខាសាលាចំនួន២ ។ សិក្ខាសាលា ទី១ គឺ សំរាប់ធ្វើការប៉ាន់ស្មានតួលេខមេរោគអេដស៍/ជំងឺអេដស៍ ក្នុងចំណោមក្រុមប្រជាជនទូទៅសំរាប់ឆ្នាំ២០១០ រីឯសិក្ខាសាលាទី២ ត្រូវបានរៀបចំឡើងដើម្បីប៉ាន់ស្មានតួលេខមេរោគអេដស៍/ជំងឺអេដស៍ សំរាប់ឆ្នាំ២០១០ ដល់ ឆ្នាំ២០១៥ ។

ក្នុងរយៈពេល៥ថ្ងៃនៃសិក្ខាសាលាលើកទី១(២៧ ខែមិថុនាដល់ ១កក្កដា ឆ្នាំ២០១១) អង្គសិក្ខាសាលាបានពិភាក្សា និងកំណត់វិធីសាស្ត្រដែលល្អបំផុត ដើម្បីធ្វើការប៉ាន់ស្មានពីស្ថានភាពមេរោគអេដស៍/ជំងឺអេដស៍ ក្នុងប្រទេសកម្ពុជា ។ លទ្ធផលចំបងនៃការប្រជុំបច្ចេកទេសនេះ គឺ រកអោយឃើញអត្រាប្រេវ៉ាឡង់មេរោគអេដស៍ ក្នុងចំណោមក្រុមប្រជាជនទូទៅនៅកម្ពុជា ក្នុងឆ្នាំ ២០១០ ។

សិក្ខាសាលាទី២ ធ្វើពីថ្ងៃទី០៦ ដល់ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១១ ។ ដោយសារពេលវេលាមានកំរិត អ្នកជំនាញឯកទេសមកពី សាកលវិទ្យាល័យ New South Wales សាកលវិទ្យាល័យ California Los Angeles និងCDC-Atlanta មិនអាចនៅចូលរួមក្នុងសិក្ខាសាលាទី២នេះ បានពេញលេញទេ ។ ទោះជាយ៉ាងណាក៏ដោយ អ្នកជំនាញឯកទេស និងទីប្រឹក្សានៅក្នុងប្រទេសទាំងអស់ ដែលបានមកចូលរួមនៅក្នុងសិក្ខាសាលាលើកទី១ ក៏បានចូលនៅក្នុងសិក្ខាសាលាលើកទី២ផងដែរ ។

## ១. ការប៉ាន់ស្មានអត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមក្រុមប្រជាជនទូទៅ

ក្រោយពេលពិនិត្យលើទិន្នន័យទាំងអស់ ដែលមាននៅក្នុងប្រទេសកម្ពុជា អ្នកជំនាញបានព្រមព្រៀង ដោយយកទិន្នន័យដែលប្រមូលបានពីស្ត្រីមានផ្ទៃពោះ ដែលទៅទទួលសេវាពិនិត្យផ្ទៃពោះនៅមណ្ឌលសុខភាព ដែលជាទិន្នន័យសមស្របជាងគេបំផុតសំរាប់ប្រើប្រាស់ក្នុងការប៉ាន់ស្មានអត្រាប្រេវ៉ាឡង់មេរោគអេដស៍/ជំងឺអេដស៍ ក្នុងចំណោមក្រុមប្រជាជនទូទៅ ។ រូបភាពខាងក្រោម បង្ហាញពីវិធីសាស្ត្រនៃការប៉ាន់ស្មានរកអត្រាប្រេវ៉ាឡង់មេរោគអេដស៍ ក្នុងចំណោមក្រុមប្រជាជនទូទៅ(១៥ ដល់ ៤៩ឆ្នាំ) ។

រូបភាពទី១. វិធីសាស្ត្រដែលប្រើប្រាស់ សំរាប់ការប៉ាន់ស្មានរកអត្រាប្រេវ៉ាឡង់មេរោគ អេដស៍ក្នុងចំណោម ក្រុមប្រជាជនទូទៅ(១៥ ដល់ ៤៩ឆ្នាំ)




## ២.វិធីសាស្ត្រសំរាប់ធ្វើការប៉ាន់ស្មានតួលេខមេរោគអេដស៍/ជំងឺអេដស៍ ឆ្នាំ២០១០-២០១៥

សិក្ខាសាលាលើកទី២ ដែលចាប់ផ្តើមពីថ្ងៃទី០៥ ដល់ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ ២០១១ បានធ្វើការប៉ាន់ស្មានអត្រាប្រេវ៉ាឡង់មេរោគអេដស៍/ជំងឺអេដស៍ ក្នុងចំណោមក្រុមប្រជាជនទូទៅ និងសូចនាករសំខាន់ៗផ្សេងៗទៀត ដែលទាក់ទងទៅនឹងមេរោគអេដស៍/ជំងឺអេដស៍ សំរាប់ឆ្នាំ២០១០ ដល់ ២០១៥ ។

វិធីសាស្ត្រចំនួន២(Asian Epidemic Model (AEM) និងSpectrum) ត្រូវបានយកមកប្រៀបធៀបគ្នា។ សំរាប់ស្ថានភាពប្រទេសកម្ពុជា វិធីសាស្ត្រទាំង២ខាងលើនេះ មានចំណុចខ្លាំង និងចំណុចខ្សោយរៀងៗខ្លួន។ នៅពេលដែល AEM អាចបង្កើតនិន្នាការនៃមេរោគអេដស៍ ដែលខិតជិតទៅនឹងនិន្នាការ ដែលអ្នកជំនាញបានសង្កេតឃើញក្នុងស្ថានភាព

ជាក់ស្តែង នៃមេរោគអេដស៍/ជំងឺអេដស៍ក្នុងប្រទេសកម្ពុជា វិធីសាស្ត្រនេះ មិនអាចបង្កើតសូចនាករ ដែលទាក់ទងទៅនឹងមេរោគអេដស៍/ជំងឺអេដស៍ បានច្រើនតាមតំរូវការចង់បានរបស់មន្ត្រីអនុវត្តកម្មវិធីជាច្រើនត្រូវការឡើយ ។ ផ្ទុយទៅវិញ Spectrum អាចផ្តល់នូវសូចនាករជាច្រើន ដែលអាចប្រើប្រាស់ ដើម្បីប្រៀបធៀបជាមួយប្រទេសជាច្រើននៅក្នុងតំបន់ រឺ ជុំវិញពិភពលោក ។ ប៉ុន្តែនិន្នាការ នៃអត្រាប្រេវ៉ាឡង់មេរោគអេដស៍/ជំងឺអេដស៍ក្នុងចំណោមក្រុមប្រជាជនទូទៅ ដែលរកឃើញដោយប្រើប្រាស់ Spectrum មិនបានដាក់បញ្ចូលនូវទិន្នន័យមេរោគអេដស៍/ជំងឺអេដស៍ ដែលទាក់ទងនឹងការប្រព្រឹត្ត និងការអនុវត្តន៍គំរោង ក្នុងចំណោមក្រុមប្រជាជនប្រឈមមុខខ្ពស់ទេ ។

អង្គសិក្ខាសាលា បានសំរេចប្រើប្រាស់វិធីសាស្ត្រទាំង២ (AEM និងSpectrum)ក្នុងការប៉ាន់ស្មានតួលេខមេរោគអដស៍/ជំងឺអេដស៍ សំរាប់ប្រទេសកម្ពុជា ។ វិធីសាស្ត្រAEM នឹងត្រូវបានប្រើប្រាស់ ដើម្បីរកអត្រាប្រេវ៉ាឡង់មេរោគអេដស៍/ជំងឺអេដស៍ ក្នុងចំណោមក្រុមប្រជាជនទូទៅ ករណីឆ្លងមេរោគអេដស៍ថ្មី និងរបៀបការចំលងមេរោគអេដស៍ក្នុងចំណោមក្រុមប្រជាជន ដែលមានអាយុចាប់ពី១៥ឆ្នាំឡើង រីឯសូចនាករផ្សេងៗទៀត នឹងត្រូវបានយកពីវិធីសាស្ត្រ Spectrum។

ដើម្បីបន្សុីវិធីសាស្ត្រ AEM និង Spectrum វាទាមទារអោយមាន ការដាក់សម្មតិកម្ម និងលក្ខខណ្ឌមួយចំនួន ដែលក្នុងនោះកត្តាធំៗបី ដែលសំខាន់ជាងគេគឺៈ ករណីឆ្លងមេរោគអេដស៍ថ្មី ករណីស្លាប់ដោយសារមេរោគអេដស៍ និងអត្រាប្រេវ៉ាឡង់មេរោគអេដស៍ ។

### រូបភាពទី២៖ វិធីសាស្ត្រដែលប្រើសំរាប់ធ្វើការប៉ាន់ស្មានតួលេខមេរោគអដស៍/ជំងឺអេដស៍




វិធីសាស្ត្រដែលប្រើប្រាស់ សំរាប់ធ្វើការប៉ាន់ស្មានតួលេខមេរោគអដស៍/ជំងឺអេដស៍ ចាប់ពីឆ្នាំ ២០១០-២០១៥ ខុសពីវិធីសាស្ត្រ ដែលប្រើនៅក្នុងការប៉ាន់ស្មានតួលេខមេរោគអេដស៍/ ជំងឺអេដស៍ នៅជុំមុនៗ ។ ភាពខុសគ្នាជាចំបងគឺ៖

ការប៉ាន់ស្មានតួលេខមេរោគអដស៍/ជំងឺអេដស៍ជុំមុនៗ គឺផ្អែកលើ វិធីសាស្ត្រតែ១ ប៉ុណ្ណោះ (Asian Epidemic Model )

ទិន្នន័យទាក់ទងនឹងប្រសិទ្ធភាព នៃការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ទៅលើការរីករាលដាលនៃមេរោគអដស៍/ជំងឺអេដស៍ នៅមិនទាន់មានច្រើននៅឡើយ ។ ដូច្នេះ ឥទ្ធិពលរបស់ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ទៅលើការប៉ាន់ស្មានតួលេខមេរោគអេដស៍/ជំងឺអេដស៍ មិនបានបញ្ចូលអោយគ្រប់ជ្រុងជ្រោយទៅក្នុងវិធីសាស្ត្រនៃការប៉ាន់ស្មានកាលពីឆ្នាំ ២០០៧ទេ ។

សំរាប់ការប៉ាន់ស្មានតួលេខមេរោគអេដស៍/ជំងឺអេដស៍លើកនេះ យើងបានប្រើវិធីសាស្ត្រ Spectrum ដែលទើបតែកែសម្រួលសារជាថ្មីឡើងវិញ ។

ទិន្នន័យដែលប្រើប្រាស់សំរាប់ធ្វើការប៉ាន់ស្មានតួលេខមេរោគអេដស៍/ជំងឺអេដស៍ សំរាប់ឆ្នាំ២០១០-២០១៥ មានច្រើនជាងការប៉ាន់ស្មាន ដែលបានធ្វើពីមុន ។

ទោះជាការប៉ាន់ស្មានតួលេខមេរោគអេដស៍/ជំងឺអេដស៍ ពីឆ្នាំ២០១០-២០១៥ មានភាពគ្រប់ជ្រុងជ្រោយសំរាប់ពន្យល់ ពីការរាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ក្នុងប្រទេសកម្ពុជា ក៏ដោយ ក៏ការប៉ាន់ស្មាននេះ នៅមានដែនកំណត់ដែរ ។ ឧទាហរណ៍ នៅពេលដែលគេគណនា ត្រលប់ទៅរកការរាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ ពីឆ្នាំមុនៗ កំរិតអត្រាប្រេវ៉ាឡង់មេរោគអេដស៍ នឹងមិនឃើញដូចគ្នាទាំងស្រុងទៅនឹងការរកឃើញនៅក្នុងការប៉ាន់ស្មានលើកមុនៗទេ ។

ក៏ប៉ុន្តែនិន្នាការ នៃការរីករាលដាលរបស់មេរោគអេដស៍ នៅតែមានភាពប្រហាក់ប្រហែលគ្នាដដែល ដូចជានៅក្នុងតួលេខប៉ាន់ស្មាន សំរាប់មេរោគអេដស៍/ជំងឺអេដស៍ ដែលធ្វើឡើងលើកចុងក្រោយបង្ហាញពីឆ្នាំ២០០៦ អត្រាប្រេវ៉ាឡង់មេរោគអេដស៍មាន ០.៩% ។ ចំពោះតួលេខថ្មី ដែលបានធ្វើការប៉ាន់ស្មានសំរាប់មេរោគអេដស៍/ជំងឺអេដស៍នៅពេលនេះ អត្រាប្រេវ៉ាឡង់មេរោគអេដស៍/ជំងឺអេដស៍សំរាប់ឆ្នាំ២០០៦មាន ១% ។ ការខុសគ្នានេះគឺបណ្តាលមកពីការប៉ាន់ស្មានសំរាប់មេរោគអេដស៍/ជំងឺអេដស៍ កាលពីមុនមិនទាន់បានបញ្ចូលអោយសព្វជ្រុងជ្រោយ នូវឥទ្ធិពលរបស់ឱសថប្រឆាំងមេរោគអេដស៍ ទៅលើអត្រាស្លាប់របស់អ្នកដែលមានផ្ទុកមេរោគអេដស៍ ។

## លទ្ធផលៈ

### ១. អត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមស្ត្រីអាយុ ១៥ ដល់ ៤៩ឆ្នាំ ក្នុងដំណាក់ការសេវាថែទាំ និងព្យាបាលជំងឺអេដស៍មានការគ្រប់ដណ្តប់ខ្ពស់

អត្រាប្រេវ៉ាឡង់មេរោគអេដស៍/ជំងឺអេដស៍ក្នុងចំណោមក្រុមប្រជាជនទូទៅ អាយុ ១៥ ដល់ ៤៩ ឆ្នាំ ត្រូវបានគណនា ដោយប្រើប្រាស់តាមតារាងខាងក្រោម ។ ការគណនានេះ គឺផ្អែកលើអត្រាប្រេវ៉ាឡង់មេរោគអេដស៍/ជំងឺអេដស៍ក្នុងចំណោមក្រុមស្ត្រីមកពិនិត្យផ្ទៃពោះ ឆ្នាំ២០០៦ និង២០១១ ។

លទ្ធផលដែលទទួលបានគឺ អត្រាប្រេវ៉ាឡង់មេរោគអេដស៍ នៅចំណោមស្ត្រីទូទៅ អាយុ ១៥ ដល់ ៤៩ឆ្នាំមាន១% នៅឆ្នាំ ២០០៦ និង០.៨% នៅឆ្នាំ២០១០ ។

**តារាងទី១៖ សង្ខេបទិន្នន័យសំរាប់ការប៉ាន់ស្មានមេរោគអេដស៍ របស់ស្ត្រីទូទៅ នៅក្នុងកំឡុងពេលដែលសេវាថែទាំ និងព្យាបាលជំងឺអេដស៍ដែលមានការគ្រប់ដណ្តប់ខ្ពស់**

| | ២០០៦ | ២០១០ |
|---|---|---|
| ចំនួនស្ត្រីអាយុ ១៥ ដល់ ៤៩ (សរុប) | ៣,៥៥៨,១២៦ | ៣,៧៨២,៤២១ |
| ចំនួនស្ត្រីមកពិនិត្យផ្ទៃពោះ (ចំនួនសរុបស្ត្រីមានផ្ទៃពោះ) | ៣៨២,៤៩៩ | ៣៦៥,០០៤ |
| ភាគរយនៃស្ត្រីមានផ្ទៃពោះមានផ្ទុកមេរោគអេដស៍(ការអង្កេត២០១០) (adjusted for QC and urban rural) | ០.៧៣% | ០.៣៦% |
| ចំនួនស្ត្រីមានផ្ទៃពោះមានផ្ទុកមេរោគអេដស៍ (ftW+FuWu) | ២,៧៧៦.៩៤ | ១,៣១៤.០១ |
| ភាគរយស្ត្រីមានផ្ទុកមេរោគអេដស៍ដែលបានទទួលសេវាថែទាំ និងព្យាបាលជំងឺអេដស៍មុនពេលមានផ្ទៃពោះ | ១០% | ៤០% |
| ភាគរយស្ត្រីមានផ្ទុកមេរោគអេដស៍ដែលមិនបានទទួលសេវាថែទាំ និងព្យាបាលជំងឺអេដស៍មុនពេលមានផ្ទៃពោះ | ៩០% | ៦០% |
| ចំនួនស្ត្រីមានផ្ទៃពោះមានផ្ទុកមេរោគអេដស៍ ដែលមិនបានទទួលសេវាថែទាំ និងព្យាបាលជំងឺអេដស៍ (FtWt) | ២,៤៩៩.២៥ | ៧៨៨.៤១ |
| អត្រាស្ត្រីមានផ្ទៃពោះ/ស្ត្រី១០០នាក់(Fn) | ១០.៧៥% | ៩.៦៥% |
| អត្រាកាត់បន្ថយភាពមានផ្ទៃពោះរបស់ស្ត្រី | ០.៨ | ០.៨ |
| អត្រាស្ត្រីមានផ្ទៃពោះ/ស្ត្រីផ្ទុកមេរោគអេដស៍១០០នាក់ (Fu) | ៨.៦% | ៧.៧២% |
| ចំនួនស្ត្រីទូទៅអាយុ ១៥ដល់៤៩ឆ្នាំ មានផ្ទុកមេរោគអេដស៍ហើយមិនបានទទួលសេវ៉ាថែទាំ និងព្យាបាលជំងឺអេដស៍ (Wu) | ២៩,០៦១ | ១០,២១៣ |
| ចំនួនស្ត្រីផ្ទុកមេរោគអេដស៍ហើយបានទទួលេសវ៉ាថែទាំ និងព្យាបាលជំងឺអេដស៍(Wt) | ៩,១៥៧ | ២០,៦០៣ |
| ចំនួនស្ត្រីផ្ទុកមេរោគអេដស៍ហើយបានទទួលេសវ៉ាថែទាំ និងព្យាបាលជំងឺអេដស៍ adjust for duplication 10%(Wt) | ៨,២៤១ | ១៨,៥៤៣ |
| ចំនួនសរុបរបស់ស្ត្រីមានផ្ទុកមេរោគអេដស៍ (Wt+Wu) | ៣៧,៣០២ | ២៨,៧៥៥ |
| **ភាគរយនៃអ្នកផ្ទុកមេរោគអេដស៍ក្នុងចំណោមស្ត្រីទូទៅ** | **១.០%** | **០.៨%** |

កំណត់សំគាល់៖ ភាគរយនៃអ្នកផ្ទុកមេរោគអេដស៍ ដែលបានទទួលសេវាថែទាំ និងព្យាបាលជំងឺអេដស៍មុនពេលមានផ្ទៃពោះ និងភាគរយស្ត្រីមានផ្ទុកមេរោគអេដស៍ ដែលមិនបានទទួលសេវាថែទាំ និងព្យាបាលជំងឺអេដស៍ មុនពេលមានផ្ទៃពោះត្រូវបាន សន្មត់ដោយផ្អែកលើការព្រមព្រៀងរបស់អង្គសិក្ខាសាលា ។ ទោះជាយ៉ាងណាក៏ដោយ ក៏ភាគរយដែលបានដាក់គឺ ធានាថា វានឹងធ្វើអោយភាគរយស្ត្រីមានផ្ទៃពោះ ដែលបាន ទទួលសេវាថែទាំ និងព្យាបាលជំងឺអេដស៍ ក្នុងចំណោមចំនួនស្ត្រីមានផ្ទៃពោះសរុប រក្សាបាននូវ កំរិតត្រឹម ៣% ។

យើងបានសន្មត់ថា ចំនួនអ្នកទទួលសេវាថែទាំ និងព្យាបាលជំងឺអេដស៍ ដែលរាយការណ៍មកពីមណ្ឌលផ្តល់សេវាថែទាំ និងព្យាបាលជំងឺអេដស៍មាន ១០% ដែលបានរាយការណ៍ជាន់គ្នា ។

ដោយផ្អែកលើអនុបាត នៃអត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមស្ត្រីទៅបុរសដែលមានជំងឺរបេងមាន ១ ទល់នឹង ១, អត្រាប្រេវ៉ាឡង់មេរោគអេដស៍នៅក្នុងចំណោមបុរសទូទៅ ក៏ដូចជាអត្រាប្រេវ៉ាឡង់មេរោគអេដស៍នៅក្នុងចំណោមក្រុមប្រជាជនដែរ មាន ០.៨% ។

**រូបភាពទី៣៖អត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមប្រជាជនទូទៅអាយុ១៥ដល់៤៩ ក្នុងឆ្នាំ២០១០**




## ២. តួលេខប៉ាន់ស្មានអត្រាប្រេវ៉ាឡង់មេរោគអេដស៍ ក្នុងចំណោមក្រុមប្រជាជនទូទៅ អាយុ ១៥ ដល់ ៤៩ឆ្នាំ

អត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមក្រុមប្រជាជនទូទៅ អាយុ១៥ ដល់ ៤៩ ឆ្នាំ ត្រូវបានគណនា ដោយប្រើប្រាស់វិធីសាស្រ្ត Spectrum ។ រីឯអត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមក្រុមប្រជាជនទូទៅអាយុ ពី១៥ឆ្នាំឡើងទៅ ជាលទ្ធផលត្រូវបានយកមកពី AEM model ។

រូបភាពទី៤៖ និន្នាការនៃអត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមប្រជាជនទូទៅអាយុ១៥ ដល់ ៤៩ឆ្នាំ (from spectrum)




រូបភាពទី៥៖ និន្នាកានៃអត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមប្រជាជនទូទៅអាយុ ១៥ឡើងទៅ (from AEM)




17

តាមការប៉ាន់ស្មានអត្រាប្រេវ៉ាឡង់មេរោគអេដស៍ មានការធ្លាក់ចុះ ហើយសន្ទុះនៃការធ្លាក់ចុះមានសភាពយឺតៗចាប់ពី ០.៨% ក្នុងឆ្នាំ ២០១០ រហូតដល់ ០.៦% ក្នុងឆ្នាំ ២០១៥ ។ បន្ថែមពីលើនេះ ចំណុចដែលគួរចាប់អារម្មណ៍ គឺអត្រាប្រេវ៉ាឡង់មេរោគអេដស៍

ក្នុងចំណោមក្រុមប្រជាជនទូទៅអាយុ១៥ឡើង និងអាយុ១៥ ដល់ ៤៩ឆ្នាំ មាន ០.៦% នឹងមានតំលៃស្មើគ្នានៅឆ្នាំ ២០១៥ ។

រូបភាពទី៦៖ និន្នាការនៃអត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមក្រុមប្រជាជនទូទៅ តាមក្រុមអាយុ




រូបភាពទី៧៖ ចំនួនប្រជាជនទូទៅដែលបានឆ្លងមេរោគអេដស៍ក្នុងចំណោមអ្នកមានអាយុ១៥ឆ្នាំឡើង **(from Spectrum)**



### រូបភាពទី៨៖ ចំនួនប្រជាជនទូទៅដែលមានផ្ទុក មេរោគអេដស៍ចាប់ពីអាយុ ១៥ ឆ្នាំឡើងទៅ (Spectrum)




### រូបភាពទី៩៖ ចំនួនអ្នកជំងឺអេដស៍ក្នុងចំណោមប្រជាជនទូទៅអាយុ១៥ឆ្នាំឡើង (from Spectrum)



**រូបភាពទី១០៖ ចំនួនអ្នកជំងឺអេដស៍ដែលត្រូវការឱសថប្រឆាំងមេរោគអេដស៍ អាយុចាប់ពីអាយុ ១៥ ឆ្នាំ ឡើងទៅ**




**រូបភាពទី១១៖ ចំនួនអ្នកស្លាប់ដោយសារមេរោគអេដស៍ ក្នុងចំណោមមនុស្សពេញវ័យអាយុ១៥ឆ្នាំឡើង(from Spectrum)**




ការផ្លាស់ប្តូរនូវនិយាមនៃការផ្តល់ឱសថប្រឆាំងមេរោគអេដស៍ ឲ្យដល់អ្នកផ្ទុកមេរោគអេដស៍ដែលមាន CD4 ២៥០ មកនៅត្រឹមចំនួន៣៥០ នៅក្នុងឆ្នាំ ២០១០ បានធ្វើអោយចំនួនអ្នកផ្ទុកមេរោគអេដស៍ ដែលត្រូវការឱសថប្រឆាំងមេរោគអេដស៍មាន

ការកើនឡើង ពី ៥១.៣១៧ នាក់នៅក្នុងឆ្នាំ ២០១០ ដល់ ចំនួន ៥៧.៩៧១ នាក់ នៅក្នុងឆ្នាំ ២០១៥ ។

**រូបភាពទី១២៖ ចំនួនកុមារដែលមានផ្ទុកមេរោគអេដស៍ ដែលមានអាយុចាប់ពី ០-១៤ ឆ្នាំ (Spectrum)**




**រូបភាពទី១៣៖ ចំនួនអ្នកជំងឺអេដស៍ក្នុងចំណោមកុមារដែលមានអាយុចាប់០ ដល់ ១៤ឆ្នាំ (from Spectrum)**




តាមវិធីសាស្ត្រ Spectrum គេបានធ្វើការប៉ាន់ស្មានថាចំនួនកុមារ ដែលមានផ្ទុកមេរោគអេដស៍ពីអាយុ ០ឆ្នាំ- ១៤ឆ្នាំ ។ នៅក្នុងឆ្នាំ២០១០កុមារដែលមានផ្ទុកមេរោគអេដស៍

ចំនួន៨.៥១២ នាក់  និងនៅក្នុងឆ្នាំ ២០១៥ កុមារដែលមានផ្ទុកមេរោគអេដស៍មានត្រឹមតែ ៥.៨៩៧នាក់។

**រូបភាពទី១៤៖ ចំនួនកុមារដែលមានផ្ទុកមេរោគអេដស៍ អាយុចាប់ពី ០-១៤ ឆ្នាំ  ត្រូវការសេវាឱសថប្រឆាំង មេរោគអេដស៍ (Spectrum)**




ចំនួនជំងឺអេដស៍កុមារដែលត្រូវការឱសថប្រឆាំងមេរោគអេដស៍នៅថេរ ចាប់ពីឆ្នាំ ២០១០ ដល់ ២០១៥ ។

**រូបភាពទី១៥៖ ចំនួនអ្នកស្លាប់ដោយសារមេរោគអេដស៍ ក្នុងចំណោមកុមារអាយុ ០ ដល់ ១៥ឆ្នាំ**



### រូបភាពទី១៦៖ ចំនួនកុមារកំព្រាដោយសារមេរោគអេដស៍ សរុប




### រូបភាពទី១៧៖ ការប៉ាន់ស្មានចំនួនស្ត្រី មានផ្ទៃពោះដែលមានផ្ទុកមេរោគអេដស៍ដែលបានទទួលសេវា **PMTCT**



## រូបភាពទី១៨៖ ការប៉ាន់ស្មានអត្រាឆ្លងមេរោគអេដស៍ពីម្តាយទៅកូន (from Spectrum)




## រូបភាពទី១៩៖ ប្រភេទនៃការ ចំលងមេរោគមេរោគអេដស៍ក្នុងចំណោមអ្នកឆ្លង ថ្មី



## រូបភាពទី២០៖ ចំនួនករណីឆ្លងថ្មីបែងចែកទៅតាមប្រភពចំលងមេរោគអេដស៍




## រូបភាពទី២១៖ ភាគរយនៃករណីឆ្លងថ្មីបែងចែកតាមប្រភពនៃការឆ្លងមេរោគអេដស៍




| | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| Mother to child | 1577 | 1568 | 1504 | 1411 | 1296 | 1170 | 1012 | 730 | 551 | 422 | 307 | 216 | 136 | 111 | 95 | 82 |
| Needle sharing | 104 | 109 | 110 | 111 | 113 | 116 | 119 | 121 | 121 | 120 | 120 | 122 | 125 | 128 | 131 | 134 |
| Male-male sex | 21 | 21 | 21 | 22 | 21 | 21 | 20 | 20 | 19 | 18 | 17 | 16 | 15 | 14 | 13 | 12 |
| Casual sex | 509 | 451 | 428 | 403 | 375 | 347 | 319 | 291 | 264 | 239 | 216 | 194 | 173 | 154 | 138 | 122 |
| Wife->husband | 651 | 624 | 614 | 595 | 569 | 537 | 502 | 465 | 428 | 390 | 352 | 316 | 282 | 250 | 222 | 196 |
| Husband->wife | 2792 | 2142 | 1773 | 1446 | 1165 | 929 | 735 | 581 | 462 | 372 | 305 | 257 | 223 | 198 | 183 | 173 |
| Sex work | 1965 | 1580 | 1403 | 1247 | 1104 | 970 | 844 | 727 | 618 | 538 | 482 | 436 | 394 | 355 | 320 | 289 |

# ការពិភាក្សា

និន្នាការនៃអត្រាប្រេវ៉ាឡង់មេរោគអេដស៍ដែលបានធ្វើការប៉ាន់ស្មាននេះគឺ វាប្រហាក់ប្រហែលគ្នាទៅនឹងនិន្នាកានៃអត្រាប្រេវ៉ាឡង់មេរោគអេដស៍ ដែលបានធ្វើការប៉ាន់ស្មាននាពេលកន្លងមកដែរ ។ ភាពស្រដៀងគ្នាដែលសំខាន់ៗទាក់ទងនឹងស្ថានភាពជំងឺអេដស៍ និង មេរោគអេដស៍ នៅក្នុងប្រទេសកម្ពុជាគឺៈ វាមានភាពស្រដៀងគ្នា នៅត្រង់ឆ្នាំដែលមានការរីករាលដាលខ្លាំង ហើយ និង និន្នាការទូទៅរបស់អត្រាប្រេវ៉ាឡង់ ។ ឧទាហរណ៍ មេរោគអេដស៍ មានការរីករាលដាលខ្លាំងត្រង់ចំណុចមួយគឺនៅវង្វង់ ឆ្នាំ១៩៩៨ ដល់ ១៩៩៩ ហើយនិន្នាកាទូទៅរបស់វាបានបង្ហាញឲ្យឃើញថា ការរាតត្បាតនៃមេរោគអេដស៍ បានថយចុះបន្តិចម្តងៗ ។

មានកត្តាពីរដែលកំណត់សន្ទុះធ្លាក់ចុះរបស់អត្រាផ្ទុកមេរោគអេដស៍ ដែលកត្តាទាំងពីរនោះគឺ អត្រាប្រេវ៉ាឡង់មេរោគអេដស៍ និងឥទ្ធិពលរបស់ការព្យាបាលជំងឺអេដស៍ ដោយឱសថប្រឆាំងមេរោគអេដស៍ និងការព្យាបាលជំងឺឱកាសនិយម ។ ដោយសារមណ្ឌលផ្តល់សេវាថែទាំ និងព្យាបាលជំងឺអេដស៍ បានគ្របដណ្តប់ជាច្រើនកន្លែង វាបានធ្វើឲ្យអ្នកផ្ទុកអេដស៍ អាចរស់រានមានជីវិតបានយូរនឹងធ្វើឲ្យចំនួនអ្នកផ្ទុកមេរោគអេដស៍ នៅថេរ ។ ការប៉ាន់ស្មានលើកចុងក្រោយរកឃើញថា មានអត្រាប្រេវ៉ាឡង់មេរោគអេដស៍ ក្នុងឆ្នាំ២០០៦មាន ០.៩% ប៉ុន្តែប្រសិនជាយើងធ្វើការគណនា អត្រាប្រេវ៉ាឡង់មេរោគអេដស៍ត្រឡប់ទៅឆ្នាំ២០០៦វិញ ដោយប្រើប្រាស់ទិន្នន័យឆ្នាំ២០១០នេះ យើងឃើញថា អត្រាប្រេវ៉ាឡង់មេរោគអេដស៍នៅឆ្នាំ២០០៦ មានប្រហែលជា១% ដែលវាខ្ពស់ជាងការគណនា ដែលបានធ្វើការប៉ាន់ស្មានកាលពីមុន ។ ការគណនា រកអត្រាប្រេវ៉ាឡង់របស់ក្រុមប្រជាជនទូទៅនៅឆ្នាំ២០០៦ មានអត្រាទាប ដោយសារក្នុងរយៈពេលនោះ ឥទ្ធិពលនៃការប្រើប្រាស់ឱសថប្រឆាំង មេរោគអេដស៍ ដែលធ្វើឲ្យអ្នកផ្ទុកអេដស៍រស់រានមានជីវិតបានយូរមិនទាន់ត្រូវបានដាក់ បញ្ចូលអោយគ្រប់ជ្រុងជ្រោយនៅឡើយ ។

ជាងនេះទៅទៀត កត្តាដែលជះឥទ្ធិពលលើអត្រាប្រេវ៉ាឡង់នៃមេរោគអេដស៍ ដែលត្រូវបានប៉ាន់ស្មានពីការប៉ាន់ស្មានមួយទៅការប៉ាន់ស្មានមួយទៀតគឺ ការកែសំរួលលើវិធីសាស្រ្តដែលប្រើប្រាស់ ដោយសារអ្នកបង្កើតគំរូវិធីសាស្រ្តទាំងនោះ បានបង្កើនសមត្ថភាពនៃវិធីសាស្រ្តគំរូរបស់គេ ។ បន្ថែមពីលើនេះ ការផ្លាស់ប្តូរនៃការគ្របដណ្តប់

នៃកម្មវិធីដូចជាការព្យាបាល ដោយឱសថប្រឆាំងមេរោគអេដស៍ ការធ្វើតេស្តរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត ការបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូនក៏មានឥទ្ធិពលទៅលើល្បឿននៃការរាលដាល និងនិន្នាការនៃអត្រាប្រេវ៉ាឡង់ផងដែរ។

ការថយចុះនៃអត្រាប្រេវ៉ាឡង់នៃមេរោគអេដស៍នៅប្រទេសកម្ពុជា អាចជាលទ្ធផលនៃកត្តាជាច្រើន ។ ការថយចុះនៃអត្រាប្រេវ៉ាឡង់នៃមេរោគអេដស៍នៅក្នុងដំណាក់កាលដំបូងនៃការរីករាលដាល អាចដោយសារការស្លាប់នៃអ្នកផ្ទុកមេរោគអេដស៍ និងដោយសារជោគជ័យនៃការ បង្ការការឆ្លងមេរោគអេដស៍ និងការផ្លាស់ប្តូរការប្រព្រឹត្តផងដែរ ដែលធ្វើអោយចំនួន នៃករណីឆ្លងថ្មីកាន់តែតិចទៅៗ ។ រហូតមកដល់ពេលថ្មីៗនេះ (២-៣ឆ្នាំ កន្លងមកនេះ) ចំនួនអ្នកស្លាប់ដោយសារជំងឺអេដស៍ ត្រូវបានថយចុះយ៉ាងច្រើន ដោយសារការពង្រីកកម្មវិធីផ្តល់ការព្យាបាល ដោយឱសថប្រឆាំងមេរោគអេដស៍យ៉ាងទូលំទូលាយ និងគុណភាពដ៏ល្អនៃសេវានេះ ។ ដោយហេតុនេះ អ្នកផ្ទុកមេរោគអេដស៍អាចរស់បានយូរ ដែលធ្វើអោយចំនួនអ្នកផ្ទុកមេរោគអេដស៍នៅថេរ។ ជាងនេះទៅទៀត ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ក៏មានប្រសិទ្ធិភាពក្នុងការកាត់បន្ថយភាពចំលងនៃអ្នកដែលមានផ្ទុកមេរោគអេដស៍ផងដែរ ដែលអាចនាំទៅរកការថយចុះនូវចំនួននៃករណីឆ្លងថ្មី ដែលចំលងដោយដែលមានអ្នកផ្ទុកមេរោគអេដស៍ស្រាប់ ។ ការប៉ាន់ស្មានពីរបៀបចំលងនៃមេរោគអេដស៍បានបង្ហាញថា សមាមាត្រនៃករណីឆ្លងមេរោគអេដស៍ថ្មីដែលខ្ពស់ជាងគេគឺនៅតែជាការឆ្លងតាមការរួមភេទ ។ បន្ថែមពីលើនេះ ការចំលងមេរោគអេដស៍ក្នុងចំណោមដៃគូរួមភេទ ដែលជួបដោយចៃដន្យ មានចំនួនកើនឡើង គួរអោយកត់សំគាល់ ។

# ការសន្និដ្ឋាន

និន្នាការរបស់អត្រាប្រេវ៉ាឡង់មេរោគអេដស៍នៅប្រទេសកម្ពុជា បានបន្តធ្លាក់ចុះរហូតដល់ឆ្នាំ២០១៥ ។ ការធ្លាក់ចុះ ដែលឃើញក្នុងឆ្នាំ ២០០៦ ដល់ ឆ្នាំ២០១៥ គឺបណ្តាលមកពី៖

១.  ការកើនឡើងនូវ  ការគ្របដណ្តប់របស់សេវាថៃទាំនិងព្យាបាលអ្នកជំងឺអេដស៍ដែលនាំឲ្យ មានការថយចុះនូវការចំលងមេរោគអេដស៍។

២.  ការអនុវត្តនូវសកម្មភាពបង្ការ  ការចំលងមេរោគអេដស៍នៅក្នុងចំណោមក្រុមគោលដៅ ទទួលបានជោគជ័យ(Condom program, VCCT, PMTCT/linke response, 3Is, STI care, outreach program, ect.)៕

៣. ការថយចុះនូវចំនួនអ្នកឆ្លងមេរោគដស៍ថ្មី។

តួលេខប៉ាន់ស្មានដែលបានគណនាគិតចាប់ពីឆ្នាំ ២០១០ ដល់ ឆ្នាំ ២០១៥ បានបង្ហាញឲ្យឃើញថា  អត្រាប្រេវ៉ាឡង់មេរោគមានការថយចុះ  ហើយអត្រាឆ្លងថ្មីក៏មានការថយចុះដែរ ។ ប៉ុន្តែសន្ទុះនៃការធ្លាក់ចុះ បានចុះថយហើយការស្លាប់ដោយសារជំងឺអេដស៍មានអត្រាកាន់ទាបទៅៗ ។

ម្យ៉ាងវិញទៀតថ្វីបើ អត្រាប្រេវ៉ាឡង់ផ្ទុកមេរោគអេដស៍និង អត្រាឆ្លងថ្មីមានការថយចុះ  ក៏ចំនួនអ្នកដែលត្រូវការថ្នាំប្រឆាំងមេរោគអេដស៍  (មនុស្សពេញវ័យ  និងកូនក្មេង) មានការកើនឡើង  រហូតដល់ឆ្នាំ២០១៥  ។  តំរូវការថវិការសំរាប់ថៃទាំ  និងព្យាបាលជំងឺអេដស៍នឹងមានការកើនឡើង ដើម្បីធានាបាននូវកម្មវិធីបង្ការជំងឺអដស៍ ។ ដូច្នេះរាជរដ្ឋាភិបាលកម្ពុជា  និងដៃគូអភិវឌ្ឍន  គួរតែរៀបចំយន្តការធានាអោយមានធនធានគ្រប់គ្រាន់និងការគាំទ្របច្ចេកទេស  ដើម្បីធានាថា  សេវាថៃទាំនិងព្យាបាលជំងឺអេដស៍អាចដំណើរការទៅបាន ទោះជាពិភពលោកកំពុងតែជួបវិបត្តិសេដ្ឋកិច្ចក៏ដោយ៕